**សកម្មភាព** ៖ **ល្បែងហេតុអ្វីមានភ្លៀងធ្លាក់?**
**វិទ្យាសាស្ត្រ**
ការរស់នៅប្រចាំងថ្ងៃ (ការស្វែងយល់ដោយសង្កេត)
បំណិនពិចារណា (ការយល់ដឹងអំពីហេតុ និងផល)
**គោលបំណង** ៖
**(វិទ្យាសាស្ត្រ)** ប្រាប់បានពីរបៀបនៃការពិសោធន៍។
លក្ខណៈរបស់អាកាសធាតុ ស្ថានភាពវត្ថុអ្វីមួយ។
**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់។
**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "តើនរណាជាអ្នកលាបពណ៌មេឃ?"
**រយៈពេល** ៖ ៣០ នាទី
**ឧបករណ៍** ៖ កែវជ័រ ទឹកធម្មតា ទឹកដែលមានពណ៌ និងពពុះកោពុកមាត់
**ការរៀបចំ** ៖ ប្រមូលវត្ថុទាំងអស់ ចាក់លាយឱ្យក្មេងៗមើលផ្ទាល់។

**សេចក្ដីណែនាំ៖**

1. ថ្ងៃនេះអ្នកគ្រូនឹងលេង**ល្បែងហេតុអ្វីមានភ្លៀងធ្លាក់?**ជាមួយកូនៗតាំងអស់គ្នា។
2. បង្ហាញឧបករណ៍មួយចំនួនឱ្យក្មេងៗមើលមាន កែវជ័រ ទឹកធម្មតា ទឹកដែលមានពណ៌ និងពពុះកោរពុកមាត់។
3. បន្ទាប់មកចាក់ទឹកចូលក្នុងដបប្លាស្ទិច ឬកែវជ័រឱ្យជិតពេញ។
4. រួចហើយបាញ់ពពុះកោរពុកមាត់ចូលទៅលើទឹកក្នុងកែវឱ្យពេញកែវ។
5. ចាក់ទឹកដែលមានពណ៌នៅលើកែវពពុះកោរពុកមាត់។
6. នៅទីបំផុតវានឹងធ្វើឱ្យទឹកពណ៌ខ្លាំងនោះស្រក់ចូលក្នុងទឹកខាងក្រោម។
7. អ្នកគ្រូពន្យល់ថាពពុះកោរពុកមាត់តំណាងឱ្យពពក និងទឹកពណ៌តំណាងឱ្យទឹកភ្លៀង។

**កត់សម្គាល់៖**
ភ្ជាប់សកម្មភាពនេះទៅនឹងសន្លឹកកិច្ចការល្បែងផាត់ពណ៌វដ្តឥន្ទធនូ។